**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**
**លេខ: ៧៦ សសរ ក.ស.វ.**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋាននៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត

## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
## ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៩៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការតែងតាំងនិងផ្តល់ឋានៈដល់សមាសភាពថ្នាក់ដឹកនាំ និងសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- បានឃើញសេចក្តីសម្រេចលេខ១៦០ សសរ ក.ស.វ.ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



អាសយដ្ឋាន: អគារមិត្តភាព លេខ៤១ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: Friendship Building, #41, Russian federation Blvd, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ/ទូរសារ: (៨៥៥)-២៣ ២១១ ៩៤៣
Tel/Fax: (855) 23 211 943

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលសរសេរជាអក្សរកាត់ថា ល.ក.ប.ល. ។

**ប្រការ២.-**

ល.ក.ប.ល. មានសមាសភាពនិងតួនាទីភារកិច្ចដូចខាងក្រោម៖

**ក- សមាសភាព**

| | | |
|---|---|---|
| ១. ឯកឧត្តម **ប៉ិច សុខា** | សមាជិកក.ស.វ.និងជាអគ្គលេខាធិការរង | ប្រធាន |
| ២. ឯកឧត្តម **អេង រត្នមុនី** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក.ស.វ. | អនុប្រធាន |
| ៣. ឯកឧត្តម **ឡោ ប៉ូលីណា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក.ស.វ. | អនុប្រធាន |
| ៤. ឯកឧត្តម **ហេង វិជ្ជា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក.ស.វ. | អនុប្រធាន |
| ៥. ឯកឧត្តម **សំ សំណាង** | ប្រធានផ្នែកលិខិតបទដ្ឋានគតិយុត្ត នៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ៦. លោក **ពិន សុធា** | ប្រធានផ្នែកសិក្សា ស្រាវជ្រាវ និងអង្កេត នៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ៧.លោក **គង់ វីរៈ** | ប្រធានផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ៨.លោក **ហេង សុតៈបញ្ញា** | ប្រធានផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ៩. លោក **អៀង រដ្ឋា** | ប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងពត៌មាននៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ១០. លោក **ឃឹម ច័ន្ទតារា** | អនុប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងពត៌មាននៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ១១.លោក **អ៊ុំ វិចិត្រ** | មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |
| ១២.កញ្ញា **ហៃ ស្រីល័ក្ខ** | មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.វ. | សមាជិក |

១៣.កញ្ញា **អ៊ឹង សុគន្ធាវី** មន្ត្រីស្ម័គ្រចិត្តនៃអគ្គលេខាធិការដ្ឋានក.ស.វ. ជំនួយការ

**ខ- តួនាទីនិងភារកិច្ច**

- ជាសេនាធិការឱ្យក.ប.ល.លើការងារប្រចាំថ្ងៃ និងដំណើរការទូទៅរបស់ក.ប.ល.
- រៀបចំសេចក្តីព្រាងកម្មវិធីបណ្តុះបណ្តាល ផ្សព្វផ្សាយ ជូនក.ប.ល. ពិនិត្យសម្រេច
- ទំនាក់ទំនង សម្របសម្រួល និងជួបប្រជុំជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួង ស្ថាប័ន ក្នុងកម្រិតបច្ចេកទេស
- ជួបប្រជុំជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីប្រមូលព័ត៌មាន ទិន្នន័យ ជូន ក.ប.ល. ពិនិត្យសម្រេច
- រៀបចំសេចក្តីព្រាងផែនការមេ ផែនការសកម្មភាព និងគម្រោងថវិកាកម្មវិធីសម្រាប់កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(វ.ផ.ល.) ជូន ក.ប.ល. ដើម្បីពិនិត្យសម្រេច
- រៀបចំប្រភពមូលដ្ឋានទិន្នន័យ ថែរក្សា និងធ្វើបច្ចុប្បន្នកម្មទិន្នន័យ សម្រាប់គាំទ្រដល់ការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំសេចក្តីព្រាងរបាយការណ៍អំពីវឌ្ឍនភាពនៃកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ជូន ក.ប.ល. ដើម្បីពិនិត្យសម្រេច
- ជំនួយការឱ្យក្រុមការងារតាមវិស័យរបស់ក.ស.វ. ដើម្បីពិនិត្យនិងផ្តល់យោបល់លើរបាយ-ការណ៍វាយតម្លៃបឋមឬពេញលេញលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដែលរៀបចំដោយក្រសួងស្ថាប័ន
- សិក្សាស្រាវជ្រាវការអនុវត្តវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃបណ្តាប្រទេសផ្សេងៗ ជូន ក.ល.ប.
- រៀបចំនិងកែលម្អមេរៀនសម្រាប់បណ្តុះបណ្តាលឱ្យទាន់សភាពការវិវត្ត ជូន ក.ប.ល. ដើម្បីពិនិត្យសម្រេច
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូន ក.ប.ល . ដើម្បីពិនិត្យសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៣.-**

ល.ក.ប.ល. ប្រើប្រាស់កញ្ចប់ថវិការបស់ក.ស.វ. សម្រាប់ដំណើរការ។

**ប្រការ៤.-**

ប្រធាន អនុប្រធាន សមាជិក លេខាធិការនៃក.ប.ល. អនុប្រធានប្រចាំការ អនុប្រធានទីប្រឹក្សាបច្ចេកទេស សមាជិកនៃក.ស.វ. អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក មន្ត្រី មន្ត្រីជាប់កិច្ចសន្យា មន្ត្រីស្ម័គ្រចិត្តរបស់អគ្គលេខាធិការដ្ឋាននៃក.ស.វ និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**យឹម ណុលឡា**

**ចម្លងជូន**:

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួង ស្ថាប័ន
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ